**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# ញត្តិគាំទ្រ

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមធ្វើការប្រកាសគាំទ្រដល់ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ដែលបានបដិសេធចោលបណ្តឹងរបស់គណបក្សភ្លើងទៀន និងគណបក្សមហាសាមគ្គីជាតិខ្មែរជុំវិញបណ្តឹងតវ៉ាក្នុងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧។

ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៅពេលនេះ បង្ហាញពីភាពម៉ឺងម៉ាត់ក្នុងការអនុវត្តគោលការណ៍នីតិរដ្ឋនៅកម្ពុជា និងគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់របស់គណបក្សនយោបាយទាំងអស់ បន្ទាប់ពីក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសម្រេចបដិសេធ ដោយសារបណ្តឹងតវ៉ារបស់គណបក្សទាំងពីរខាងលើពាក់ព័ន្ធនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ខុសនឹងគតិច្បាប់។

ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមគាំទ្ររាល់ចំណាត់ការ ឬការសម្រេចចិត្តក្នុងបុព្វហេតុលើកកម្ពស់នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដែលធានាការពារយ៉ាងរឹងមាំដោយរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមានទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីជាគ្រឹះដ៏រឹងមាំនៃការរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ សិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការអភិវឌ្ឍជាតិមាតុភូមិកម្ពុជាជារៀងដរាបតរៀងទៅ៕

ថ្ងៃព្រហស្បតិ៍ ៦កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ៘

ព្រះរាជាណាចក្រកម្ពុជា ក្រសួងមុខងារសាធារណៈ

ផ្លូវវិត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh